## កម្ពុជា៖ រសជាតិល្វីងនៃស្ករអំពៅ

# ការចាកចេញដោយបង្ខំចិត្ត និងការដកហូតសិទ្ធិកាន់កាប់ដីធ្លី ក្នុងខេត្តឧត្តរមានជ័យ



# សម្បទានដីសេដ្ឋកិច្ច និងសហគមន៍ព្រៃឈើ ខេត្តឧត្តរមានជ័យ







**Legend**

- Cambodia Cane and Sugar Valley
- Angkor Sugar
- Tonle Sugar Cane
- Community forestry

## សេចក្តីសង្ខេប

ដីធ្លីនៅតែបន្តជាបញ្ហាវិវាទដ៏ធំនៅប្រទេសកម្ពុជា ហើយសម្បទានដីសេដ្ឋកិច្ច (ELCs) គឺជាមេខ្លោងធំជាងគេដែលជម្រុញអោយមានការទន្ទ្រានយកដីធ្លី នៅក្នុងកំឡុងពេលពីរទសវត្សរ៍ចុងក្រោយនេះ។ គិតមកដល់ត្រឹមខែធ្នូ ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សម្បទានដីធ្លីប្រមាណជាង ២.៦ លានហិកតា ស្មើនិង ១៤.៣ភាគរយនៃផ្ទៃដីសរុបប្រទេសកម្ពុជាដល់ក្រុមហ៊ុនឯកជនក្នុងទម្រង់ជាសម្បទានដីសេដ្ឋកិច្ចសម្រាប់ធ្វើការវិនិយោគវិស័យកសិ-ឧស្សាហកម្មផ្សេងៗ ហើយដែលគួរអោយកត់សម្គាល់នោះគឺការបង្កើតឡើងនៃចំការឯកវប្បកម្មរួមមានដូចជា កៅស៊ូ ចំការអំពៅ ដំឡូងមី និងល្ហុងប្រេង។ គោលបំណងមួយនៃសម្បទានដីសេដ្ឋកិច្ចគឺ ដើម្បី *"អភិវឌ្ឍន៍សកម្មភាព កសិកម្ម និងឧស្សាហកម្ម-កសិកម្ម អតិផល និងដើម្បីបង្កើនការងារនៅតំបន់ជនបទ ក្រោមគោលការណ៍ប្រពលវប្បកម្ម និងភាពចម្រុះ នៃឱកាសចិញ្ចឹមជីវិត និងក្រោមគោលការណ៍គ្រប់គ្រងធនធានធម្មជាតិដែលផ្អែកទៅលើប្រព័ន្ធអេកូឡូស៊ីសមស្រប"*។ ប៉ុន្តែផ្ទុយពីគោលដៅខាងលើការសិក្សាស្រាវជ្រាវ និងចងក្រងឯកសារដោយសង្គមស៊ីវិល ជាពិសេសក្រុមសិទ្ធិមនុស្ស និងអ្នកស្រាវជាវបានបង្ហាញថាសម្បទានដីសេដ្ឋកិច្ចជាកត្តាបង្ក អោយមានការដកហូតសិទ្ធិកាន់កាប់ដីឯកជននិងដីសមូហភាព ការចាកចេញដោយបង្ខំចិត្តរបស់កសិករខ្នាតតូចនិងសហគមន៍ជនជាតិដើមភាគតិចដែលមានដីធ្លីតិចតួច ការបាត់បង់ផ្ទះសម្បែង ដីធ្លី និងអចលទ្រព្យ ការអន់ថយនៃជីវភាពប្រចាំថ្ងៃ និងការបាត់បង់ប្រភពចំណូល និងការកើនឡើងនៃអសន្តិសុខស្បៀង និងភាពក្រីក្រ។ល។ របាយការណ៍បានបង្ហាញថា ចាប់តាំងពីឆ្នាំ ២០០០ ប្រជាជនប្រមាណជាង ៧០០,០០០នាក់ ត្រូវបានដកហូតសិទ្ធិកាន់កាប់ដីធ្លីដោយសារតែការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅទូទាំងប្រទេស។

ចំពោះសម្បទានដីសេដ្ឋកិច្ចទាំងអស់នេះ សម្បទានដីសេដ្ឋកិច្ចសម្រាប់ឧស្សាហកម្មចំការអំពៅ ត្រូវបានរកឃើញថាជាបុព្វហេតុដ៏អាក្រក់មួយដែលនាំអោយមានការរាតត្បាតនៃការទន្ទ្រានយកដីធ្លីនៅកម្ពុជា។ ចាប់តាំងពីឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ដីសម្បទានច្រើនជាង ១១៤,០០០ហិកតា តាមរយៈសម្បទានដីសេដ្ឋកិច្ចចំនួន ១៩កន្លែងសម្រាប់ធ្វើចំការអំពៅ។ ក្នុងចំណោមនោះ សម្បទានដីសេដ្ឋកិច្ចដែលទទួលបានចំណាប់អារម្មណ៍ខ្លាំងជាងគេ គឺសម្បទានដីសេដ្ឋកិច្ចសម្រាប់ចំការអំពៅនៅក្នុងខេត្តកោះកុង ខេត្តកំពង់ស្ពឺ និងខេត្តឧត្តរមានជ័យ ដែលមានទំនាក់ទំនងផ្ទាល់ជាមួយ និងគោលការណ៍អនុគ្រោះកម្មវិធីពាណិជ្ជកម្ម "អ្វីគ្រប់យ៉ាងលើកលែងតែអាវុធ" (Everything But Arms) របស់សហភាពអឺរ៉ុប សំរាប់ប្រទេសអភិវឌ្ឍន៍តិចបំផុត ដែលក្រុមហ៊ុនស្ករនៅប្រទេសថៃ និង/រឺតៃវ៉ាន់ ចាប់ដៃគូជំនួញជាមួយនិងអ្នកជំនួញកម្ពុជាដែលមានអំណាចបានបង្កើតឧស្សាហកម្មចំការអំពៅចំនួនប្រាំពីរកន្លែងតាមរយៈកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចដើម្បីផលិតស្ករនៅសម្រាប់នាំចេញទៅកាន់ទីផ្សារនៅសហភាពអឺរ៉ុប។

ការសិក្សានេះផ្តោតជាពិសេសទៅលើសម្បទានដីសេដ្ឋកិច្ចសម្រាប់ចំការអំពៅនៅក្នុងខេត្តឧត្តរមានជ័យ។ កាលពីខែមករាឆ្នាំ២០០៨ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់សម្បទានដីសេដ្ឋកិច្ចចំនួនបីកន្លែងដែលមានផ្ទៃដីសរុប ១៩,៧៣៦ហិកតា ដែលស្ថិតនៅក្នុងស្រុកសំរោង និងស្រុកចុងកាល ខេត្តឧត្តរមានជ័យ អោយទៅក្រុមហ៊ុនចំនួនបីគឺ ក្រុមហ៊ុនអង្គរស៊ូហ្គើរ ក្រុមហ៊ុនខេន អេនស៊ូហ្គើរវ៉ាលី និងក្រុមហ៊ុនទន្លេស៊ូហ្គើរខេន សម្រាប់ធ្វើការបង្កើតចំការអំពៅ និងរោងចក្រច្នៃស្ករអំពៅក្នុងរយៈពេល ៧០ឆ្នាំ។ ការសិក្សានេះបានរកឃើញថាការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ចំការអំពៅទាំងបីកន្លែង នៅក្នុងខេត្តឧត្តរមានជ័យបាន៖

- ធ្វើអោយប៉ះពាល់ដល់ប្រជាពលរដ្ឋច្រើនជាង**២,០៧៣ គ្រួសារ** ដែលរស់នៅក្នុង**ភូមិចំនួន ២៦** ក្នុងឃុំសំរោង ឃុំកូនគ្រៀល ឃុំពង្រ និងឃុំចុងកាល។

- នាំអោយមានការទន្ទ្រានយកដីធ្លី និងការដកហូតសិទ្ធិកាន់កាប់នៃដីកសិកម្ម ដីចម្ការ និងដីផ្ទះសម្បែង ដែលមានផ្ទៃដីប្រមាណ **៩,៤៣០ហិកតា** ក្នុងភូមិរងផលប៉ះពាល់ទាំង ២៦។
- នាំអោយមានការទន្ទ្រានយក **ដីព្រៃសហគមន៍ច្រើនជាង ៧,៩៤៤ហិកតា** ដែលត្រូវបានស្នើរសុំ និងបម្រុងទុកអោយសហគមន៍ព្រៃឈើរតនៈរុក្ខា នៅក្នុងឃុំសំរោង និងឃុំកូនគ្រៀល។
- **បង្ករការដុតបំផ្លាញភូមិ** ការបណ្តេញចេញ **និងការចាកចេញដោយបង្ខំចិត្តនៃប្រជាពលរដ្ឋចំនួន ២១៤គ្រួសារ** ក្នុងភូមិ អូរបាត់មាន់/បុស្ស ក្នុងឃុំកូនគៀល។
- **បង្ករអោយមានការដោះដូរដីធ្លីដោយបង្ខំ**ដែលមានផ្ទៃដី **ចំនួនជាង ៣, ៥៤៨ហិកតា** ដោយបង្ខិតបង្ខំដល់គ្រួសារដែលរស់នៅក្នុងភូមិរងផលប៉ះពាល់ អោយទទួលយកដីដោះដូរដែលមានទំហំតូចជាង និងមានគុណភាពអន់ជាងដីធ្លីរបស់ពួកគេ។
- **បណ្តាលអោយបាត់បង់ផ្ទះសំបែង អចលនទ្រព្យ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដំណាំ** និងបានបង្កអោយមាន**ការបាត់បង់ប្រភពចំណូលនិងជីវភាពប្រចាំថ្ងៃ** ក៏ដូចជាការកើនឡើងនៃអសន្តិសុខស្បៀង និងភាពក្រីក្រ ដែលនាំអោយមានការធ្វើចំណាកស្រុកកាន់ច្រើនឡើងទៅប្រទេសថៃ ដើម្បីស្វែងរករបរចិញ្ចឹមជីវិតដែលមិនពឹងផ្អែកលើដីធ្លី។
- សម្បទានិក បានចុះកិច្ចសន្យាកាប់ព្រៃឈើជាមួយនិងក្រុមហ៊ុនមិនស្គាល់ឈ្មោះមួយ ដើម្បីធ្វើការប្រមូលផលឈើប្រណិត និងបង្កើតរោងចក្រកែច្នៃឈើប្រណិតនៅលើដីសម្បទានរបស់ក្រុមហ៊ុនអង្គរស៊ូហ្គើរ។ គិតមកត្រឹមខែវិច្ឆិកា ឆ្នាំ២០១៤ ក្រុមហ៊ុននេះបានកាប់ព្រៃនៅ**លើផ្ទៃដីព្រៃឈើផិត ៣,១៩០ហិកតា** ដែលស្ថិតក្នុងតំបន់ដីសម្បទាន និងបានកែច្នៃឈើទាំងនោះទៅជាឈើកំណល់ផ្លូវរថភ្លើង សម្រាប់នាំចេញទៅប្រទេសថៃ។ គ្មានរោងចក្រកែច្នៃស្ករណាមួយ ត្រូវបានកសាងនោះទេ ហើយ**មានតែផ្ទៃដី ២១៩ហិកតា ដែលស្មើនិង ១.១ ភាគរយ** នៃផ្ទៃដីសម្បទានសរុបប៉ុណ្ណោះត្រូវបានប្រើប្រាស់សម្រាប់ដាំសំណាកអំពៅ បន្ទាប់មកសំណាកអំពៅទាំងនោះត្រូវបានកាប់និងដុតចោល ហើយដីសម្បទាននោះត្រូវបានប្តូរទៅដាំដំឡូងមីវិញ។
- បង្ករអោយមានការរំលោភបំពានច្បាប់ និងបទដ្ឋានជាតិ និងអន្តរជាតិមួយចំនួន ដែលក្នុងនោះរួមមានច្បាប់ភូមិបាលឆ្នាំ២០០១ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦ និងច្បាប់ស្តីពីព្រៃឈើឆ្នាំ២០០២។ ការរំលោភបំពានលើតម្រូវការនៃនិតិវិធីរបស់ច្បាប់នានា ក្នុងការធានាការគោរពសិទ្ធិមនុស្ស **មុនពេល កំឡុងពេល និងក្រោយពេលនៃការបណ្តេញចេញ** ដូចដែលមានចែងនៅក្នុង *គោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្តីពីការបណ្តេញចេញ និងការចាកចេញដោយបង្ខំផ្អែកលើការអភិវឌ្ឍន៍ឆ្នាំ ២០១២។*តម្រូវការនៃនិតិវិធីទាំងនេះប្រកាន់ខ្ជាប់នូវសិទ្ធិទទួលបានសន្តិសុខនៃបុគ្គល និងផ្ទះសំបែងដែលត្រូវបានការពារដោយកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលកម្ពុជាមានកាតព្វកិច្ចត្រូវគោរពតាម។
- បង្ករអោយការរំលោភបំពានសិទ្ធិមនុស្ស របស់គ្រួសារទាំងឡាយ។

**ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់កំពុងស្វែងរកដំណោះស្រាយដូចខាងក្រោមពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសគឺគណៈកម្មការអន្តរក្រសួង និងក្រុមហ៊ុនសម្បទានិកទាំងបី (តាមរយៈក្រុមហ៊ុនមេ មីតផល ភូល (Mitr Phol) និងសហភាពអឺរ៉ុប៖**

**១)ធ្វើការលុបចោលជាផ្លូវការ និងជាបន្ទាន់ នៃសម្បទានដីសេដ្ឋកិច្ចសម្រាប់ឧស្សាហ៍កម្មចំការអំពៅទាំងបី។**

**២)ធ្វើការវាយតម្លៃ គ្រប់ជ្រុងជ្រោយនិងប្រកបដោយតម្លាភាព លើអំណះអំណាងនៃការបាត់បង់ផ្ទះសំបែង ដីធ្លី ទ្រព្យសម្បត្តិ និងប្រភពចំណូលនិងជីវភាពប្រចាំថ្ងៃ** របស់អ្នកភូមិ ដែលរងផលប៉ះពាល់ពីសម្បទានដីសេដ្ឋកិច្ចសម្រាប់ឧស្សាហ៍កម្មចំការអំពៅទាំងបី។ ចំណែកគ្រួសាររងផលប៉ះពាល់ឯទៀត ដែលមិនបានរាប់បញ្ចូលក្នុងការ

សិក្សានេះ គួរតែទទួលបានការពិគ្រោះយោបល់ និងវាយតម្លៃ លើការអះអាងនៃការបាត់បង់ ផ្ទះសម្បែង ដីធ្លី ទ្រព្យសម្បត្តិ និងចំណូលផងដែរ។ បន្ទាប់មកគួរតែរៀបចំ និងអនុវត្ត**នូវផែនការសកម្មភាពដោះស្រាយ**ត្រឹមត្រូវ មានប្រសិទ្ធភាពនិងមានការកំណត់ពេលវេលាជាក់លាក់ដោយផ្អែកលើបញ្ជីទី១ និងបញ្ជីទី២ ស្តីពីៈ "ការដោះដូរដីធ្លី" ដែលក្នុងនោះរួមមានដូចខាងក្រោម៖

**២.១ ការរៀបចំយន្តការជាក់លាក់ត្រឹមត្រូវនិងមានតម្លាភាពមួយស្តីពីការទាមទារសំណងជួសជុលការខូចខាតដែលសិទ្ធិកាន់កាប់ដីធ្លីស្របច្បាប់លើផ្ទៃដីទំហំ៩,៤៣០ហិកតា** នៃដីកសិកម្ម ដីចម្ការ និងដីផ្ទះសំបែងដែលបានទន្ទ្រានយកកន្លងមក ត្រូវបានដោះស្រាយនិងធ្វើការវាស់វែង ហើយសិទ្ធិកាន់កាប់ពេញលេញក្នុងទម្រង់ជាប័ណ្ណកម្មសិទ្ធិរបស់អ្នកកាន់កាប់ស្របច្បាប់លើផ្ទះសំបែង ដីកសិកម្ម និងដីចម្ការ ត្រូវបានស្តាបនាឡើងវិញ និងសិទ្ធិអាស្រ័យផលលើដីចម្ការក៏ត្រូវបានស្តាបនាឡើងវិញផងដែរតាមរយៈដំណើរការចុះបញ្ជីកម្មសិទ្ធិដីធ្លីជាប្រព័ន្ធ (SLR) ពីព្រោះថាខេត្តឧត្តរមានជ័យនាពេលបច្ចុប្បន្ននេះ កំពុងតែប្រតិបត្តិការដំណើរការនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីជាប្រព័ន្ធ។ ប្រជាពលរដ្ឋរងផលប៉ះពាល់បានបញ្ជាក់យ៉ាងច្បាស់ពីការទាមទាររបស់ពួកគាត់ថា ពួកគាត់ត្រូវការយកដីធ្លីមកវិញ ពួកគាត់មិនត្រូវការសំណងជាសាច់ប្រាក់នោះទេ។

**២.២ ការត្រួតពិនិត្យឡើងវិញនិងប្រកបដោយតម្លាភាពចំពោះដីដែលបានដោះដូរទំហំ ៣,៥៨៨ហិកតា** ដែលប្រជាពលរដ្ឋរងផលប៉ះពាល់បានទទួលយក ក្រោមការបង្ខិតបង្ខំក្នុងកំឡុងពេលដំណើរនៃការដោះដូរដីធ្លី។ ការត្រួតពិនិត្យនេះអាចអោយគ្រួសារនីមួយៗទទួលបាន ក)ដីដោះដូរពេញលេញមានគុណភាព ទំហំ និងតម្លៃប្រហាក់ប្រហែលទៅនិងដីធ្លីដើម ដែលពួកគាត់បាត់បង់និង/រី ខ)ទទួលបានដីធ្លីដើមរបស់ពួកគាត់វិញ។ ជម្រើសនេះគឺផ្អែកទៅតាមការសម្រេចចិត្តបានរបស់គាត់។

**២.៣ ការរៀបចំបង្កើតឡើងនូវយុទ្ធសាស្រ្តមួយស្តីពីការស្តារនិតិសម្បទានៃដីព្រៃសហគមន៍ចំនួន ៧, ៩៤៤ហិកតា** ដែលត្រូវបានទន្ទ្រានយកដោយក្រុមហ៊ុនសម្បទានិក និងការបង្កើតឡើងនៃយន្តការមួយ សំរាប់**ធ្វើការប្រគល់**ដីព្រៃសហគមន៍នេះ ត្រលប់ទៅអោយសមាជិកសហគមន៍ព្រៃឈើរតនៈរុក្ខា ដើម្បីធ្វើការគ្រប់គ្រងនិងប្រើប្រាស់។

**២.៤ ការទូទាត់សំណងជាប្រាក់ប្រកបដោយភាពយុត្តិធម៌ និងសមស្របទៅនិងការបាត់បង់ផ្ទះសម្បែង អចលនទ្រព្យ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងដំណាំ** របស់ប្រជាពលរដ្ឋចំនួន២១៤គ្រួសារដែលរស់នៅក្នុងភូមិអូរបាត់មាន់/ប៊ុស្ស ឃុំកូនក្រៀល ដោយទ្រព្យទាំងនោះត្រូវបានបាត់បង់ និងត្រូវបានដុតបំផ្លាញ ។

**២.៥ ការត្រួតពិនិត្យឡើងវិញ ដែលគ្រប់ជ្រុងជ្រោយ ឯករាជ្យ និងមានតម្លាភាព លើការបាត់បង់ ប្រភពចំណូល និងជីវភាពប្រចាំថ្ងៃ** ដែលបង្កឡើងដោយការបាត់បង់ដីធ្លី និងដំណាំ និងការបាត់បង់សិទ្ធិប្រើប្រាស់ព្រៃសហគមន៍ដែលបណ្តាលអោយប្រជាពលរដ្ឋមិនអាចប្រមូល ជ័រទឹកនិងអនុផលព្រៃឈើនានា។ ការរៀបចំបង្កើតយន្តការនៃការទូទាត់សំណងជាសាច់ប្រាក់ និងកម្មវិធីស្តារជីវភាពប្រចាំថ្ងៃ និងបង្កើនប្រភពចំណូល។

**២.៦ ជំនួយការអភិវឌ្ឍន៍នៅក្នុងភូមិដែលរងផលប៉ះពាល់** ដូចជា៖

**ក.** កសាងប្រព័ន្ធធារាសាស្រ្តអោយប្រសើរជាងមុន ពីព្រោះប្រជាពលរដ្ឋរងផលប៉ះពាល់ជាច្រើននាក់ ត្រូវពឹងផ្អែកលើកត្តាធម្មជាតិ និងមានលទ្ធភាពធ្វើការប្រមូលផលស្រូវត្រឹមតែមួយដងប៉ុណ្ណោះក្នុងមួយឆ្នាំនៅរដូវវស្សា ហើយមិនអាចធ្វើបាននៅរដូវប្រាំងបានទេ។

**ខ.** ពង្រឹងមធ្យោបាយដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋានរួមទាំងការប្រើប្រាស់ផ្លូវថ្នល់ ដូច្នេះប្រជាពលរដ្ឋអាចដឹកជញ្ជូនស្រូវ និងដំណាំផ្សេងៗទៀតពីដីកសិកម្ម និងដីចម្ការរបស់ពួកគាត់ចូលទៅកាន់ទីផ្សារបានងាយស្រួល។

គ. ផ្តល់ចំណេះដឹង និងជំនាញបច្ចេកទេស សំរាប់ពង្រឹងជីវៈចម្រុះ និងទិន្នផលនៃផលិតផលកសិកម្ម។
ឃ. បង្កើនលទ្ធភាពនៃការចូលទៅដល់ទីផ្សារប្រកួតប្រជែង និងពង្រឹងអំណាចក្នុងការចរចារតម្លៃផលិតផលជាមួយអ្នកទិញ និងម្ចាស់បំណុល និងការចែករំលែកឧបករណ៍ ដើមទុនរវាងកសិករ ។ល។
ង. ឱកាសចូលរួមក្នុងការឡើងទៅលើខ្សែចង្វាក់ផ្គត់ផ្គង់ផលិតផល

បន្ថែមពីលើការ ជួសជុលព្យសនកម្ម និងការជួសជុសសំណងការខូចខាតដោយផ្ទាល់ទៅអោយ ប្រជាពលរដ្ឋរងផលប៉ះពាល់ រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាអភិវឌ្ឍន៍ និងលើកកម្ពស់កម្មវិធីអភិវឌ្ឍន៍និងវិនិយោគវិស័យកសិកម្មបែបថ្មី។

## ៣.ការអភិវឌ្ឍន៍និងលើកកម្ពស់កម្មវិធីអភិវឌ្ឍន៍និងវិនិយោគវិស័យកម្មបែបថ្មី

មានការសន្មត់ជាមូលដ្ឋានថា ការអភិវឌ្ឍន៍វិស័យកសិកម្មក្រោមទម្រង់ សម្បទានដីសេដ្ឋកិច្ចជាការធ្វើសាជីវកម្មផលិតផលកសិកម្មទ្រង់ទ្រាយធំនោះ ជាដំណោះស្រាយដ៏សមស្របជាងគេសម្រាប់កម្ពុជា។ ប៉ុន្តែនេះ មិនមែនជាការពិតនោះទេ។ តាមរយៈបទពិសោធ៍ពីប្រទេសឡាវ និងវៀតណាម បានបង្ហាញអោយឃើញថាអាជីវកម្មផលិតស្រូវរបស់កសិករខ្នាតតូចមានប្រសិទ្ធិភាពខ្ពស់ជាង និងអាចធ្វើការប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិបាន។ ចំនុចទីពីរដែលប្រហែលជាមានសារៈសំខាន់ជាងនេះ ទៅទៀតគឺយុទ្ធសាស្រ្តបែបនេះ មិនទំនងជាអាចពង្រឹងសន្តិសុខស្បៀងក្នុងប្រទេសកម្ពុជាបានទេ ពីព្រោះលក្ខខណចម្បងនៃបញ្ហាសន្តិសុខស្បៀង គឺថាកសិករក្រីក្រខ្នាតតូចនៅជនបទភាគច្រើន មិនមានលទ្ធភាពរកបាន និងគ្មានលទ្ធភាពប្រើប្រាស់ស្បៀង និងវត្ថុធាតុដើមសំរាប់ផលិត ស្បៀងជាពិសេស គឺភាពចម្រុះនៃគ្រាប់ពូជដំណាំនិងជីវ។ កត្តាចម្បងនៃបញ្ហានេះ ពាក់ព័ន្ធតិចតួចទៅនិងបរិមាណនៃការផលិត។ ហេតុនេះតម្រូវអោយរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុនជ្រើសរើសយុទ្ធសាស្រ្តបែបថ្មីផ្សេងទៀត ដើម្បីការធ្វើវិនិយោគវិស័យកសិកម្ម ដែលមិនផ្តោតលើដី ប៉ុន្តែផ្តោតច្រើនជាងទៅលើប្រជាពលរដ្ឋ ដែលបច្ចុប្បន្នពួកគាត់កំពុងធ្វើកសិកម្មលើដីទាំងនេះ និងផ្តោតលើទំនៀមទម្លាប់របស់ពួកគាត់ក្នុងការផលិតស្បៀង។ ប្រជាពលរដ្ឋអាចនឹងធ្វើការផលិតផលិតផលកសិកម្មបានច្រើន ប្រសិនបើពួកគាត់ទទួលបានឧបករណ៍និងចំណេះដឹងបច្ចេកទេសត្រឹមត្រូវដែលរួមមានការអនុវត្តន៍ "កសិកម្មនិរន្តភាពដែលធន់នឹងការប្រែប្រួលអាកាសធាតុ"។

រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញពីការប្តេជ្ញារបស់ខ្លួនក្នុងការដោះស្រាយបញ្ហារំលោភសិទ្ធិមនុស្ស ដែលកើតឡើងតាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលមិនបានគោរពទៅតាមគោលការណ៍ច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការ ដើម្បីធ្វើការពិនិត្យឡើងវិញ និងលុបចោលសម្បទានដីសេដ្ឋកិច្ចជាច្រើនចាប់តាំងពីឆ្នាំ២០១២មក ហើយបានដាក់អោយអនុវត្តន៍យន្តការ "បទបញ្ជា ០១" ដែលជាពិសេសគឺការបង្កើតគណៈកម្មការអន្តរក្រសួង ក្នុងខែមករាឆ្នាំ ២០១៤ ដើម្បីដោះស្រាយបញ្ហាដែលកើតចេញពីសម្បទានដីសេដ្ឋកិច្ចសម្រាប់ចំការអំពៅដែលមានកិច្ចសហប្រតិបត្តិការជាមួយនិងសហភាពអ៊ឺរ៉ុប។

ការបង្កើតឡើងនូវផែនការជាក់លាក់ ដើម្បីដោះស្រាយបញ្ហាពីសំណាក់រដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុនសម្បទានិកទាំងបី (តាមរយៈក្រុមហ៊ុនមេ Mitr Phol) និងសហភាពអ៊ឺរ៉ុបដើម្បីឆ្លើយតបទៅនិងអនុសាសន៍ចំបងទាំងបី និងចំនុចលម្អិតទាំងប្រាំមួយដែលបានបង្ហាញក្នុងរបាយការណ៍នេះ គឺជាសញ្ញាតំណាងអោយជំហានដ៏សំខាន់មួយ ឆ្ពោះទៅកាន់គណនេយ្យភាពរបស់ក្រុមទទួលខុសត្រូវផ្នែកសង្គម របស់ក្រុមហ៊ុនសម្បទានិកចំពោះបញ្ហារំលោភសិទ្ធិមនុស្ស និងការឆ្ពោះទៅកាន់ការផ្តល់នូវភាពយុត្តិធម៌ ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកសំរោង និងស្រុកចង់កាល ខេត្តឧត្តរមានជ័យ ដែលទទួលរងការរំលោភបំពានសិទ្ធិមនុស្សបង្កឡើងដោយការទន្ទ្រានយកដីធ្លី សម្រាប់ធ្វើសម្បទានដីសេដ្ឋកិច្ចសម្រាប់ចំការអំពៅស្ករ។


K93-219
Planting Date
24-10-12



#69, St 242,
Sangkat Chaktomuk, Khan Daun Penh, Phnom Penh
Cambodia
Tel: (+855) 23 994 987
Email: e-mail.cambodia@actionaid.org